# យុទ្ធនាការបញ្ឈប់ការប្រើថង់ប្លាស្ទីក
# នឹងធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៥

វត្តបទុម រាជធានីភ្នំពេញ (ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៥)៖ យុទ្ធនាការបញ្ឈប់ការប្រើថង់ប្លាស្ទីក នឹងត្រូវបានប្រារព្ធធ្វើនៅវត្តបទុមរាជធានីភ្នំពេញ។

យុទ្ធនាការនេះមានគោលបំណងដើម្បីកាត់បន្ថយប្លាស្ទីក និងទម្លាប់ការកែច្នៃក្នុងចំណោមសង្គមកម្ពុជា ព្រំទាំងលើកកម្ពស់ចំណេះដឹងរបស់ពលរដ្ឋមិនត្រូវបានចោលសម្រាមឥតសណ្ដាប់ធ្នាប់ ការកាត់បន្ថយ និងការកែច្នៃកាកសំណល់ប្លាស្ទីក។ ការិយាល័យអង្គការយូណេស្កូប្រចាំកម្ពុជា ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត និងសហភាពសហព័ន្ធយុវជននៅក្នុងប្រទេសកម្ពុជាបានរួមគ្នារៀបចំ "យុទ្ធនាការបញ្ឈប់ការប្រើថង់ប្លាស្ទីក" ដែលបានគាំទ្រដោយក្រុមហ៊ុន Coca-Cola ផ្សារទំនើបសូរិយា ផ្សារទំនើបបាយ័ន និងផ្សារទំនើបថៃហួត។ យុទ្ធនាការនេះនឹងលើកទឹកចិត្តប្រជាជនកម្ពុជាឲ្យចេះពិចារណាលើការកាត់បន្ថយកាកសំណល់ និងការកែច្នៃប្លាស្ទីក ជាលទ្ធផលដែលសំខាន់ក្នុងការផ្លាស់ប្ដូរឥរិយាបទ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

គោលបំណងរបស់យុទ្ធនាការនេះគឺ៖

- ដើម្បីបង្កើនការយល់ដឹងលើការកាត់បន្ថយប្លាស្ទីកនិងការកែច្នៃ ព្រមទាំងការផ្លាស់ប្ដូរឥរិយាបថរបស់ប្រជាជនកម្ពុជា។
- ដើម្បីលើកទឹកចិត្តដល់ប្រជាជនកម្ពុជា ពិសេសយុវវ័យ ក្នុងក្របខ័ណ្ឌនៃកម្មវិធី "យុទ្ធនាការយុវជននិងទីក្រុងស្អាត" ដើម្បីចែករំលែកគំនិតនៃការគ្រប់គ្រងកាកសំណល់ប្លាស្ទីកនៅក្នុងក្រុមគ្រួសាររបស់ពួកគេ។
- ដើម្បីបង្កើនមធ្យោបាយដោះស្រាយកាកសំណល់ប្លាស្ទីក។
- ដើម្បីបង្កើតការយល់ដឹងពីវិធីផ្សេងគ្នានៃការផលិត និងការប្រើប្រាស់ប្លាស្ទីក។
- ដើម្បីអភិវឌ្ឍជំនាញក្នុងការត្រិះរិះពិចារណាក្នុងចំណោមសមាជិកសហគមន៍។
- ដើម្បីយល់ពីសក្ដានុពលនិងការលំបាកក្នុងការកែច្នៃផលិតផលប្លាស្ទីក។

ពិធីនេះនឹងប្រព្រឹត្តទៅនៅវត្តបទុម រាជធានីភ្នំពេញ ដោយមានសេចក្ដីថ្លែងការណ៍ខ្លីមួយទាក់ទងនឹងបញ្ហាប្លាស្ទីកនៅក្នុងប្រទេសកម្ពុជា ហើយមានការចូលរួមពីដៃគូពាក់ព័ន្ធនានា។ ទន្ទឹមនឹងនេះ ក៏នឹងមានការធ្វើបទបង្ហាញវីដេអូខ្លីពិសេសមួយស្ដីពី "ប្លាស្ទីកមិនរលាយ" ដែលបានផលិតដោយ អង្គការយូណេស្កូ មូលនិធិ Exo និងអង្គការហ្សារពន្លឺសិល្បៈ។ បន្ទាប់មក មានការជួបជុំក្រុមយុវជន ដោយពួកគេនឹងប្រមូលប្លាស្ទិចនៅក្នុងតំបន់មួយចំនួននៅក្នុងរាជធានីភ្នំពេញ ដើម្បីចូលរួមលើកកម្ពស់ការយល់ដឹងលើការ

កាត់បន្ថយកាកសំណល់ប្លាស្ទិក និងការកែឆ្នៃ។ (សូមអានរបៀបវារៈនិងផែនទី នៃកម្មវិធីដែលបានភ្ជាប់ទៅសេចក្ដីប្រកាសនេះ)។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង កញ្ញា María Iniguez de Heredia មន្ត្រីវិទ្យាសាស្ត្រផ្នែកបរិស្ថាន នៃអង្គការយូណេស្កូតាមរយៈ m.iniguez-de-heredia@unesco.org
និងកញ្ញា Nayheak Khun ក្រុមការងារទំនាក់ទំនងនៃអង្គការយូណេស្កូតាមរយៈ
n.khun@unesco.org

TENTATIVE AGENDA

FIRST CAMBODIAN ANTI-PLASTIC BAG CAMPAIGN – 27th NOVEMBER 2015

Phnom Penh – Wat Botum

FRIDAY 27 NOVEMBER 2015

07.30 Gathering of the participants

07.45 Statement by Ms. Anne Lemaistre, Representative of UNESCO in Cambodia

07.50 Statement by H.E. Hun Many, President of Union of Youth Federations in Cambodia

07.55 Statement by H.E. Say Samal, Minister of Environment

08.00 Statement by H.E Thong Khon, Minister of Tourism and Chairman of NCCA

08.05 Screening and Launching of the video clip "Plastic Waste Never Dies"

08.15 Press Conference

08.30 Starting of the plastic collection in three different places (Find below the map)

10.30 Finish of the plastic collection and gathering at Wat Botum for refreshment

**Participate in the "Cambodian Anti-Plastic Bag Campaign" for clean and green development in our country!**


ក្រុមទី១៖ ធ្វើដំណើរតាមផ្លូវឧកញ៉ា សួរ ស្រ៊ិន បន្តដល់ផ្លូវឧកញ៉ាឈុន(២៤០) បន្តតាមផ្លូវ
លេខ ១៩ (ផ្លូវក្រោយវាំង) បន្តដល់ផ្លូវលេខ ១០៦ (សួនច្បារស្មានតាត) បន្តដល់មុខផ្សាររាត្រី ។
ក្រុមទី២៖ ធ្វើដំណើរតាមវិថីសម្ដេចសុធារស បន្តដល់វាលព្រះមេរុ បន្តដល់មុខវត្តឧណ្ណាលោម
និងបន្តតាមវិថីព្រះស៊ីសុវត្ថិ ហើយបន្តដល់មុខផ្សាររាត្រី ។
ក្រុមទី៣៖ ធ្វើដំណើរតាមវិថីព្រះសុរាម្រិត បន្តដល់រង្វង់មូលសម្ដេចសង្ឃរាជជួនណាត បន្ត
ដល់វិថីព្រះស៊ីសុវត្ថិ បន្តហូតដល់មុខផ្សាររាត្រី។
ក្រុមទី១
ក្រុមទី២
ក្រុមទី៣
ទីតាំងចាប់ផ្ដើមពិធី
ទីតាំងបញ្ចប់
The Royal Palace
Silver Pagoda
Preah Ang Duong
Street 178
154 St
148 St
118 St
Kracheh - Phnom Penh
Ta Khmau - Phnom Penh